ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# អនុក្រឹត្យ

# ស្តីពី

# នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៦ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# នីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពី ការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី ២៣ ខែ មិថុនា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានការឯកភាព ពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០២

# សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១.-**

អនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី ២២ ខែ មិនា ឆ្នាំ ២០០០ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និង សៀវភៅគោលបញ្ជីដីធ្លី ត្រូវបានចាត់ទុកជានិរាករណ៍ ហើយត្រូវបានជំនួសដោយអនុក្រឹត្យនេះ ដែលកំណត់នីតិវិធីនៃការ កសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លីតាមរយៈការវិនិច្ឆ័យ ដែលមានលក្ខណៈជាប្រព័ន្ធ នៅក្នុងតំបន់ដែលបាន ប្រកាសថាជាទីតាំងធ្វើការវិនិច្ឆ័យដូចមានចែងក្នុងមាត្រា២ នៃអនុក្រឹត្យនេះ ។

**មាត្រា ២.-**

អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ នៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវកំណត់ និងណែនាំ បច្ចេកទេសជំនាញ និងទំរង់បែបបទនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ដល់មន្ទីររៀបចំដែនដី នគរូប នីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ។

អភិបាលខេត្ត ក្រុង ត្រូវចេញសេចក្តីប្រកាសកំណត់តំបន់ និងព្រំប្រទល់នៃទីតាំងធ្វើការវិនិច្ឆ័យតាមរបៀបបង្ហាញ លើផែនទី ឬតាមរបៀបពិពណ៌នា ឬតាមរបៀបទាំងពីរ ។

## ជំពូកទី ២

## សមត្ថកិច្ច និងភារកិច្ច

**មាត្រា ៣.-**

នៅពេលដែលតំបន់ត្រូវធ្វើការវិនិច្ឆ័យបានប្រកាសហើយ អភិបាលខេត្ត ក្រុងនៃតំបន់ធ្វើការវិនិច្ឆ័យ ត្រូវតែងតាំង គណៈកម្មការរដ្ឋបាលសំរាប់តំបន់ដែលត្រូវធ្វើការវិនិច្ឆ័យនោះ ។

សមាសភាពនៃគណៈកម្មការរដ្ឋបាលមាន :

- តំណាងអភិបាលខេត្ត ក្រុង ជាប្រធាន
- មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ជាមន្ត្រីសុរិយោដី ជាសមាជិក
- មន្ត្រីទទួលខុសត្រូវការងាររដ្ឋបាលសុរិយោដី នៃមន្ទីររៀបចំ ដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ជាសមាជិក
- អភិបាលស្រុក ខ័ណ្ឌ ឬតំណាង ជាសមាជិក
- មេឃុំ ចៅសង្កាត់ ឬតំណាង ជាសមាជិក
- មេភូមិ ឬតំណាង ជាសមាជិក
- ចាស់ព្រឹទ្ធាចារ្យក្នុងទីតាំងធ្វើការវិនិច្ឆ័យ ២រូប ជាសមាជិក ។

ភារកិច្ចរបស់គណៈកម្មការរដ្ឋបាលមាន :

-បិទផ្សាយជាសាធារណៈនូវប្លង់បញ្ជីសុរិយោដី ជាអាទិ៍ ប្លង់សុរិយោដី និងបញ្ជីឈ្មោះអ្នកកាន់កាប់ដី

- ទទួលរាល់បណ្តឹងតវ៉ា ធ្វើការស្រាវជ្រាវ និងដោះស្រាយតាមការព្រមព្រៀង

- ធ្វើសេចក្តីសន្និដ្ឋានផ្តល់យោបល់លើឯកសារនៃការវិនិច្ឆ័យ

- លើកសំណើផ្តល់សិទ្ធិលើដីជូនអ្នកកាន់កាប់ ជូនកម្មសិទ្ធិករ ឬរក្សាទុកជាទ្រព្យសម្បត្តិរដ្ឋ ។

**មាត្រា ៤.-**

នៅពេលដែលតំបន់ធ្វើការវិនិច្ឆ័យត្រូវបានកំណត់ហើយ អគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវចាត់តាំងមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យព្រមទាំងមន្ត្រីចាំបាច់មួយចំនួនទៀតរួមមាន : មន្ត្រីកំណត់ព្រំដី មន្ត្រីវិនិច្ឆ័យ និងមន្ត្រីវាស់វែងដែលត្រូវបំពេញភារកិច្ចក្នុងតំបន់ធ្វើការវិនិច្ឆ័យ ។

មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ដែលបានទទួលសេចក្តីណែនាំពីអគ្គនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រ ត្រូវទទួលខុសត្រូវចំពោះការវិនិច្ឆ័យដែលបានកំនត់ក្នុងអនុក្រឹត្យនេះ ។ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យមានសិទ្ធិដឹកនាំចេញសេចក្តីណែនាំចាំបាច់ដល់មន្ត្រីជំនាញ ដែលបានតែងតាំងក្នុងវាក្យខ័ណ្ឌទី ១ មាត្រា ៤ នៃអនុក្រឹត្យនេះ ។

មន្ត្រីកំណត់ព្រំដី និងមន្ត្រីវាស់វែងមានសិទ្ធិចូលក្នុងបរិវេណអចលនវត្ថុណាមួយ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ ដើម្បីកំណត់ព្រំ និងវាស់វែង ហើយអាចអញ្ជើញជនដែលពាក់ព័ន្ធឱ្យផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗ ទាក់ទងទៅនឹងព្រំនៃក្បាលដីណាមួយ ។

មន្ត្រីវិនិច្ឆ័យ មានសិទ្ធិសាកសួរយកពត៌មានចាំបាច់សំរាប់អនុវត្តការងារវិនិច្ឆ័យ អាចអញ្ជើញជនដែលពាក់ព័ន្ធអោយផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឯកសារ ឬភស្តុតាងផ្សេងៗ ទាក់ទងទៅនឹងការវិនិច្ឆ័យ ។

**មាត្រា ៥.-**

ក្នុងតំបន់ធ្វើការវិនិច្ឆ័យ ជនដែលមានការពាក់ព័ន្ធ មានកាតព្វកិច្ចចូលរួម និងសហការក្នុងការកំណត់ព្រំដី និងការវិនិច្ឆ័យ ដោយផ្តល់នូវចម្លើយដោយផ្ទាល់មាត់ ឬជាលាយលក្ខណ៍អក្សរ ឯកសារ ឬភស្តុតាងផ្សេងៗដល់មន្ត្រីជំនាញ ដើម្បីអនុវត្តការកំណត់ព្រំដី ការវាស់វែង និងការវិនិច្ឆ័យ ។

ជនគ្រប់រូបមានសិទ្ធិចូលរួមពិនិត្យ និងផ្តល់យោបល់ ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារ នៃការវិនិច្ឆ័យ និងមានសិទ្ធិសុំឱ្យមន្ត្រីជំនាញពន្យល់បំភ្លឺអំពីខ្លឹមសារ នៃទិន្នន័យដែលពាក់ព័ន្ធនឹងតំបន់ធ្វើការវិនិច្ឆ័យ ។

**មាត្រា ៦.-**

អភិបាលខេត្ត ក្រុង ត្រូវផ្ញើលិខិតផ្លូវការដែលពិពណ៌នា និងអនុញ្ញាតឱ្យអនុវត្តនីតិវិធីវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ទៅអាជ្ញាធរមូលដ្ឋាននៃតំបន់ធ្វើការវិនិច្ឆ័យយ៉ាងហោចណាស់ ១៥ (ដប់ប្រាំ) ថ្ងៃ មុនកិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យ ។

អភិបាលខេត្ត ក្រុងត្រូវជូនដំណឹងជាសាធារណៈ អំពីពេលវេលា និងទីកន្លែង នៃកិច្ចប្រជុំផ្សព្វផ្សាយ ។ សេចក្តីជូនដំណឹងត្រូវបិទឱ្យសាធារណៈជនដឹងយ៉ាងហោច ៧ (ប្រាំពីរ) ថ្ងៃ មុនបើកកិច្ចប្រជុំផ្សព្វផ្សាយ ក្នុងកន្លែងដែលងាយឃើញ

នៅក្នុងភូមិ ឬនៅទីតាំងធ្វើវិនិច្ឆ័យផ្ទាល់ ។ សេចក្តីប្រកាសត្រូវតែផ្សព្វផ្សាយឱ្យបានទូលំទូលាយ និងមានប្រសិទ្ធភាពក្នុងទីតាំងធ្វើការវិនិច្ឆ័យ ដោយសហការជាមួយអាជ្ញាធរមូលដ្ឋាន ។

កិច្ចប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំណត់តំបន់ធ្វើការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវរៀបចំធ្វើនៅក្នុងទីតាំងធ្វើការវិនិច្ឆ័យ ។ ក្នុងកិច្ចប្រជុំនោះ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ឬតំណាងគណៈកម្មការរដ្ឋបាល ត្រូវពន្យល់ពីដំណើរការនៃការវិនិច្ឆ័យ បំភ្លឺពីបញ្ញាច្បាប់ និងឆ្លើយរាល់សំណួរទាក់ទងនឹងការវិនិច្ឆ័យ ដែលបានលើកឡើង ។

កិច្ចប្រជុំបន្ថែមសំរាប់ថ្នាក់ភូមិនឹងត្រូវបានរៀបចំ ប្រសិនបើមន្ត្រីគ្រប់គ្រងការងារវិនិច្ឆ័យ ឬអាជ្ញាធរមូលដ្ឋាន ចាត់ទុកថាជាការចាំបាច់ ។

**មាត្រា ៧.-**

មន្ត្រីកំណត់ព្រំដី ត្រូវជូនដំណឹងដល់ថ្នាក់ដឹកនាំមូលដ្ឋានអំពីការកំនត់ព្រំដីក្នុងតំបន់ធ្វើការវិនិច្ឆ័យ ពេលវេលា និងទីកន្លែងដែលនឹងចាប់ផ្តើមធ្វើការវិនិច្ឆ័យឱ្យបានមុន ៧( ប្រាំពីរ) ថ្ងៃយ៉ាងតិច ។ សេចក្តីជូនដំណឹងតម្រូវឱ្យជនដែលពាក់ព័ន្ធមកចង្អុលបង្ហាញព្រំប្រទល់នៃអចលនវត្ថុរបស់ខ្លួន តាមរបៀបដែលបានបញ្ជាក់ក្នុងសេចក្តីប្រកាសជូនដំណឹង ។

បន្ទាប់មក មន្ត្រីកំណត់ព្រំដីដែលបានទទួលការណែនាំពីអ្នកគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវកំណត់ព្រំប្រទល់អចលនវត្ថុទាំងអស់ដែលបង្កើតបានជាក្បាលដីក្នុងប្លង់សុរិយោដី ។ ក្នុងរយៈពេលធ្វើការកំណត់ព្រំប្រទល់ក្បាលដីមន្ត្រីកំណត់ព្រំដីត្រូវគោរពគោលការណ៍ ដូចខាងក្រោម :

ក-បើកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលជាប់ព្រំ មានវត្តមាន ហើយព្រមព្រៀងលើព្រំប្រទល់ នោះព្រំប្រទល់នឹងត្រូវបានកំណត់យោងតាមការព្រមព្រៀង ។

ខ-បើការព្រមព្រៀងដែលរៀបរាប់ក្នុងចំណុច (ក) នៃមាត្រានេះ មិនអាចធ្វើទៅបាន ឬមានកម្មសិទ្ធិករ ឬម្ចាស់នៃក្បាលដី និងម្ចាស់នៃក្បាលដីដែលនៅជាប់ព្រំណាមួយអវត្តមាន នោះព្រំប្រទល់ត្រូវកំណត់នៅលើដី តាមឯកសារដែលមាន និងភស្តុតាងជាលក្ខណៈរូប ជាលាយលក្ខណ៍អក្សរ ឬចំលើយផ្ទាល់មាត់ទាក់ទងនឹងព្រំដី ។

គ-ចំពោះក្បាលដីដែលមានព្រំប្រទល់ជាប់ និងដីសាធារណៈ ឬក្បាលដីដែលប្រើប្រាស់ជាសាធារណៈ ព្រំប្រទល់ក្បាលដី ត្រូវកំណត់ដោយអនុលោមទៅតាមចំនុច (ក) ឬ (ខ) នៃវាក្យខ័ណ្ឌទី២ មាត្រា៧ នៃអនុក្រឹត្យនេះ ។

ឃ-វិវាទទាំងអស់ អំពីព្រំប្រទល់ដែលមិនអាចដោះស្រាយបានក្នុងពេលកំណត់ព្រំដី ត្រូវបញ្ជូនទៅធ្វើការសំរុះសំរួល និងដោះស្រាយវិវាទក្រោមមាត្រា ១២ នៃអនុក្រឹត្យនេះ ។

**មាត្រា ៨.-**

មន្ត្រីវាស់វែងដែលបានទទួលការណែនាំពីមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវអនុវត្តការងារវាស់វែងដែលជាតំរូវការក្នុងការប្រតិបត្តិនីតិវិធីវិនិច្ឆ័យ និងរៀបចំប្លង់សុរិយោដី ។

## ជំពូកទី ៣
## នីតិវិធីនៃការវិនិច្ឆ័យ

**មាត្រា ៩.-**

មន្ត្រីវិនិច្ឆ័យដែលបានទទួលការណែនាំពីមន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវអង្កេតរាល់ឯកសារ ភស្តុតាង និងពត៌មានផ្សេងៗជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់ ទាក់ទងទៅនឹងសិទ្ធិលើក្បាលដីនីមួយៗ ក្នុងតំបន់ធ្វើការវិនិច្ឆ័យ ហើយកត់ត្រាសិទ្ធិទាំងនេះ ចូលក្នុងទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។

**មាត្រា ១០.-**

ការរៀបចំឯកសារនៃការវិនិច្ឆ័យមានន័យដូចខាងក្រោម :

១-ឯកសារនៃការវិនិច្ឆ័យត្រូវមាន :

-ប្លង់សុរិយោដី

-បញ្ជីឈ្មោះម្ចាស់ដី

-ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ។ ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដីនីមួយ ៗ ត្រូវបង្ហាញ :

ក-អត្តសញ្ញាណក្បាលដី

ខ-អត្តសញ្ញាណម្ចាស់ដី

គ-កាលបរិច្ឆេទនៃការវិនិច្ឆ័យ ។

២-ទំរង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ត្រូវផ្តិតមេដៃយល់ព្រមពីម្ចាស់ដី ព្រមទាំងអ្នកជាប់ព្រំហើយ ត្រូវចុះហត្ថលេខាដោយមន្ត្រីវិនិច្ឆ័យ ។

៣-នៅពេលដែលឯកសារនៃការវិនិច្ឆ័យត្រូវបានបំពេញចប់សព្វគ្រប់ហើយ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ ត្រូវចុះហត្ថលេខាលើឯកសារទាំងនេះ ។

**មាត្រា ១១.-**

ការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យដែលរួមមាន ប្លង់សុរិយោដី និងបញ្ជីឈ្មោះម្ចាស់ដី ត្រូវមានរយៈពេល ៣០ (សាមសិប) ថ្ងៃ នៅកន្លែងដែលងាយមើលឃើញ សំរាប់ការអង្កេតជាសាធារណៈនៅក្នុងតំបន់ធ្វើការវិនិច្ឆ័យ ។

អាជ្ញាធរខេត្ត-ក្រុង ត្រូវផ្សាយដំណឹងអំពីការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ តាមសំណើរបស់គណៈកម្មការរដ្ឋបាល ។

ក្នុងរយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ មន្ត្រីគ្រប់គ្រងការងារតំបន់វិនិច្ឆ័យ អាចកែតម្រូវការខុសឆ្គង ឬការភ្លេចភ្លាំងណា ដែលមិនជះឥទ្ធិពលដល់ផលប្រយោជន៍ត្រឹមត្រូវស្របច្បាប់ នៃជនណាមួយ ។ ការ

កែតម្រូវផ្សេងៗក្នុងឯកសារនៃការវិនិច្ឆ័យ អាចធ្វើបាន ដរាបណាមានការយល់ព្រមពីជនពាក់ព័ន្ធ ដែលទទួលឥទ្ធិពលពីការកែតម្រូវនោះ ។

**មាត្រា ១២.-**

ក្នុងអំឡុងពេលនៃការបិទផ្សាយជាសាធារណៈ ជនណាដែលមានឈ្មោះក្នុងបញ្ជី ឬអ្នកដែលមានផលប្រយោជន៍លើក្បាលដីណាមួយ ដែលបានចាត់ទុកថា ឯកសារនៃការវិនិច្ឆ័យមិនជាក់លាក់ ឬមិនពេញលេញ អាចផ្តល់ដំណឹងដល់គណៈកម្មការរដ្ឋបាលនូវការជំទាស់របស់ខ្លួន ។

ក្រោយពីផ្តល់នូវការកត់សំគាល់ដ៏សមហេតុផល ដល់ជនគ្រប់រូបដែលពាក់ព័ន្ធ និងការជំទាស់ និងបន្ទាប់ពីពិគ្រោះជាមួយអ្នកដែលធ្វើការជំទាស់ គណៈកម្មការរដ្ឋបាលត្រូវព្យាយាមដោះស្រាយតាមការព្រមព្រៀង ។

ការជំទាស់ ឬវិវាទណាមួយដែលមិនអាចដោះស្រាយបាន ត្រូវបញ្ជូនទៅគណៈកម្មការសុរិយោដីថ្នាក់ជាតិ ស្របតាមនីតិវិធី ដែលនឹងកំណត់ដោយអនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី ។

**មាត្រា ១៣.-**

ក្រោយពីផុតកំណត់រយៈពេលនៃការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យ និងបញ្ចប់ការដោះស្រាយទំនាស់តាមនីតិវិធីដូចមានចែងក្នុងមាត្រា ១២ នៃអនុក្រឹត្យនេះ គណៈកម្មការរដ្ឋបាល ត្រូវផ្តល់ការយល់ព្រមលើឯកសារនៃការវិនិច្ឆ័យចំពោះក្បាលដីទាំងឡាយណាដែលមិនមានទំនាស់ ។

បន្ទាប់ពីការយល់ព្រម គណៈកម្មការរដ្ឋបាល ត្រូវបញ្ជូនឯកសារនៃការវិនិច្ឆ័យទៅមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ដើម្បីពិនិត្យលើលក្ខណៈបច្ចេកទេស និងចុះហត្ថលេខា ហើយបញ្ជូនទៅអភិបាលខេត្ត ក្រុងចុះហត្ថលេខា ។

**មាត្រា ១៤.-**

ក្រោយពីអភិបាលខេត្ត ក្រុង និងរដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ចុះហត្ថលេខាហើយឯកសារនៃការវិនិច្ឆ័យ ត្រូវបានបញ្ចប់ជាស្ថាពរចំពោះក្បាលដីដែលមិនមានទំនាស់ ។ ចំពោះឯកសារនៃការវិនិច្ឆ័យ ដែលនៅពាក់ព័ន្ធ និងវិវាទ នឹងត្រូវបញ្ចប់ជាស្ថាពរ នៅពេលមានការដោះស្រាយចប់សព្វគ្រប់ដោយគណៈកម្មការសុរិយោដី ឬដោយតុលាការ ។

នៅពេលដែលឯកសារនៃការវិនិច្ឆ័យត្រូវបានបញ្ចប់ជាស្ថាពរយោងតាមវាក្យខ័ណ្ឌទី ១ នៃមាត្រានេះ ឯកសារនៃការវិនិច្ឆ័យព្រមទាំងឯកសារទាំងអស់ ដែលទទួលបានក្នុងអំឡុងពេលនៃការវិនិច្ឆ័យដែលមានលក្ខណៈជាប្រព័ន្ធ ត្រូវបញ្ជូនទៅរដ្ឋបាលសុរិយោដី ដើម្បីចុះបញ្ជី ។

ក្រោយពេលក្បាលដីដែលមានក្នុងឯកសារនៃការវិនិច្ឆ័យ ត្រូវបានចុះបញ្ជីហើយ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ត្រូវចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុ លើគ្រប់ក្បាលដីក្នុងតំបន់ធ្វើការវិនិច្ឆ័យនេះ ។ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ អាចប្រគល់សិទ្ធិអោយខេត្ត ក្រុងណាដែលមាន

គ្រប់លក្ខណសម្បត្តិ ដើម្បីចេញវិញ្ញាបនប័ត្រសំគាល់ម្ចាស់អចលនវត្ថុ ឬប័ណ្ណសំគាល់សិទ្ធិកាន់កាប់អចលនវត្ថុនេះ នៅក្នុងតំបន់ធ្វើការវិនិច្ឆ័យនៃខេត្ត ក្រុងរបស់ខ្លួន ។

ការណែនាំអំពីរបៀបរបបនៃការកាន់កាប់ឯកសារសុរិយោដី និងឯកសារណបផ្សេងៗ នឹងកំណត់ដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ។

## ជំពូកទី ៤

## អវសានប្បញ្ញត្តិ

**មាត្រា ១៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១៦.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអភិបាលខេត្ត ក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ.ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០២

**នាយករដ្ឋមន្ត្រី**

**ហត្ថលេខា និងត្រា**

**ហ៊ុន សែន**

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី

-គ្រប់ក្រសួង ស្ថាប័នកណ្តាល

-គ្រប់សាលាខេត្ត-ក្រុង

-ដូចមាត្រា១៦

-ឯកសារ កាលប្បវត្តិ